អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១១

# សេចក្តីប្រកាសព័ត៌មាន

## ជប៉ុនសន្យាផ្តល់ជំនួយថវិកាចំនួន ២,៩ លានដុល្លារអាមេរិក ទៀត ដល់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

រាជរដ្ឋាភិបាលជប៉ុនបានសន្យាផ្តល់ជំនួយថវិកា ចំនួន ២,៩ លានដុល្លារអាមេរិកទៀត ដល់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) បន្ទាប់ពីតុលាការចាប់ផ្តើមដំណើរការនីតិវិធីលើសំណុំរឿង ០០២ ប្រឆាំងនឹងអតីតមេដឹកនាំខ្មែរក្រហមបីរូបកាលពីសប្តាហ៍មុន។

នៅក្នុងសេចក្តីប្រកាសព័ត៌មានអំពីការផ្តល់ជំនួយនេះ ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជាបានថ្លែងថា ជំនួយលើកនេះគឺផ្តល់ជូនភាគីអន្តរជាតិនៃ អ.វ.ត.ក "ដើម្បីគាំទ្រដំណើរការនីតិវិធីនៃសាលាក្តីខ្មែរក្រហម" ស្របពេលនៃការចាប់ផ្តើមសវនាការដំបូងនៃសំណុំរឿង ០០២ និងការប្រកាសសាលដីកាស្ថាពរនៃសំណុំរឿង ០០១ ដែលគ្រោងធ្វើនៅថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំក្រោយ។

ជប៉ុនគឺជាម្ចាស់ជំនួយដ៏ធំបំផុតរបស់ អ.វ.ត.ក និងបានផ្តល់ជំនួយសរុបចំនួន ៧០,៥៧ លានដុល្លារអាមេរិក ដែលស្ទើរតែស្មើនឹងពាក់កណ្តាលនៃគម្រោងថវិកាទាំងមូលរបស់ អ.វ.ត.ក។

ឯកឧត្តម ក្រាញ់ តូនី ប្រធានរដ្ឋបាលស្តីទីនៃ អ.វ.ត.ក និងលោក ឃ្នុត រ៉ូសិនហាក អនុប្រធានរដ្ឋបាល បានថ្លែងថា "យើងសូមសម្តែងអំណរគុណដោយស្មោះអស់ពីចិត្តចំពោះរាជរដ្ឋាភិបាលជប៉ុនដែលបានបន្តការគាំទ្រដ៏មានសារសំខាន់នេះដល់ អ.វ.ត.ក នៅក្នុងខណៈដែល អ.វ.ត.ក បន្តដំណើររបស់ខ្លួនជាមួយនឹងការចាប់ផ្តើមសំណុំរឿងក្តី ០០២"។ លោកបានបន្តថា "ទឹកចិត្តសប្បុរសនិងជំនួយគាំទ្រនេះមានសារសំខាន់ណាស់សម្រាប់ អ.វ.ត.ក ក្នុងការបំពេញបេសកកម្មរបស់ខ្លួនឲ្យបានជោគជ័យ"។

ថវិកានឹងត្រូវបានផ្ទេរមកតាមសន្យានាពេលឆាប់ៗខាងមុខ។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

**លោក ឡាស អូលសិន**
មន្ត្រីទំនាក់ទំនងផ្នែកច្បាប់
ទូរស័ព្ទចល័ត: +៨៥៥ (0) ១២ ៩៨៨ ០២៣
ទូរស័ព្ទ: +៨៥៥(0) ២៣ ៨១៤ លេខបន្ត: ៦១៦៩
សារអេឡិកត្រូនិក: olsenl@un.org

**លោក នេត្រ ភក្ត្រា**
អ្នកនាំពាក្យសាលាក្ដីខ្មែរក្រហម
ទូរស័ព្ទដៃ: +៨៥៥-១២ ៩៨ ៣២៨៣
សារអេឡិចត្រូនិក: neth.pheaktra@eccc.gov.kh